**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ០៦៥ សសរ.កសក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសកម្មភាពជនពិការ
## ប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ ក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- បានឃើញសេចក្តីសម្រេចលេខ៤៩ សសរ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាសកម្មភាពជនពិការ
- បានឃើញប្រកាសលេខ០០១ កសជ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារសកម្មភាពជនពិការ នៅតាមក្រសួង ស្ថាប័ន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

# សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារសកម្មភាពជនពិការប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរសេរជាអក្សរកាត់ថា **ក.ស.ជ.កសក** ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **វេង សាខុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធានកិត្តិយស |
| ២-ឯកឧត្តម | **ឡោ រស្មី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ៣-លោកជំទាវ | **យ៉ើ អស៊ីគីន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤-លោក | **ម៉ិន លាងហេង** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន | អនុប្រធាន |
| ៥-លោកស្រី | **ស៊ិន សុភ័ណ្ឌ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម | អនុប្រធាន |
| ៦-លោក | **សៀ រ៉ា** | អនុប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ៧-លោក | **អ៊ឹង ត្រី** | អនុប្រធានរដ្ឋបាលជលផល | សមាជិក |
| ៨-លោក | **ឃុន កក្កដា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ៩-លោក | **ស៊ិន សាន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ១០-លោក | **អ៊ឹង រតនា** | សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ១១-លោក | **ទី ចាន់ណា** | ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ១២-លោក | **អ៊ីន សុភា** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ១៣-លោក | **ម៉ុច បន្លា** | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ១៤-លោកស្រី | **សារ សុភីរៈ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |
| ១៥-លោក | **ឡោ សេង** | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៦-លោក | **ថៃ សាខុន** | អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិក |
| ១៧-លោកស្រី | **សុ ស្រីមុំ** | អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ | សមាជិកា |
| ១៨-លោក | **សយ សុមេធា** | អនុប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម | សមាជិក |
| ១៩-លោក | **សេង វ៉ាង** | នាយករងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ២០-លោក | **ហែម ធីរៈ** | នាយករងសាលាជាតិកសិកម្មកំពង់ចាម | សមាជិក |
| ២១-លោក | **ម៉េង សុខុន** | នាយករងសាលាជាតិកសិកម្មព្រែកលៀប | សមាជិក |
| ២២-លោក | **សរ ទិសិដ្ឋារ៉ា** | អនុប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម | សមាជិក |
| ២៣-លោក | **ព្រាប សុវណ្ណ** | មន្ត្រី នៃនាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក។ |

**ប្រការ២.-**

**ក.ស.ជ.កសក** ត្រូវចូលរួមអនុវត្តតាមខ្លឹមសារណែនាំក្នុងប្រកាសលេខ០០១ កសជ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង-ស្ថាប័ន។

**ប្រការ៣.-**

ត្រូវបានបង្កើតក្រុមលេខាធិការដ្ឋាន ជាសេនាធិការជួយដល់ដំណើរការនៃ **ក.ស.ជ.កសក** ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោក | **អ៊ុំ សាទី** | អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | ប្រធាន |
| ២-លោក | **ជា សុភ័ក្រ្ត** | ប្រធានការិយាល័យបុគ្គលិក នៃនាយកដ្ឋានកិច្ចការរដ្ឋបាល | អនុប្រធាន |

៣-លោក **ណៃ សុផុន** ប្រធានការិយាល័យតាមដានការអនុវត្ត នៃអគ្គាធិការដ្ឋាន អនុប្រធាន

៤-លោកស្រី **សម សុទ្ធារី** អនុប្រធានការិ.ហិរញ្ញកិច្ច នៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ សមាជិកា

៥-លោក **យ៉យ ស៊ីណា** អនុប្រធានការិ.នៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស លេខាធិការ។

លេខាធិការដ្ឋាននៃ **គ.ស.ជ.កសក** មានភារកិច្ចដូចខាងក្រោម៖

- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការ **គ.ស.ជ.កសក**
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗរបស់ **គ.ស.ជ.កសក**
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រដែលមានការងារពាក់ព័ន្ធនឹងពិការភាព និងការស្តារលទ្ធភាពពលកម្ម
- ជួយជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម
- សម្របសម្រួលជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុង និងក្រៅប្រទេស
- រៀបចំទិវាជនពិការជាតិ ទិវាជនពិការអន្តរជាតិ និងទិវាជនពិការផ្សេងៗទៀត
- ធ្វើរបាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពទាក់ទងនឹងពិការភាព
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការជូនក្រសួង និងចាត់ចែងបញ្ជូនរបាយការណ៍ទៅក្រុមប្រឹក្សាសកម្មភាពជនពិការ (អគ្គលេខាធិការដ្ឋាន **គ.ស.ជ**)។

**ប្រការ៤.-**

ប្រកាសលេខ១៨៨ ប្រក.កសក.ប ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥ និងប្រកាសលេខ៣៧១ ប្រក.កសក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៥ រោច ១៣៧២ ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងមុខងារសាធារណៈ
- -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
- -ដូចប្រការ៥
- -ឯកសារ កាលប្បវត្តិ